ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កែប
# រយៈពេល ៣ឆ្នាំ (មករា ២០២៦ - ធ្នូ ២០២៨)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ កែប |
| ភូមិ | ៖ កែប |
| សង្កាត់ | ៖ កែប |
| ក្រុង | ៖ កែប |
| ខេត្ត | ៖ កែប |

រៀបចំដោយរដ្ឋបាលជលផលសហការជាមួយខណ្ឌរដ្ឋបាលជលផលកែប (គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

# មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**.......... ១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.......... ២

ក- ប្រជាពលរដ្ឋ.......... ២

ខ- មុខរបរ.......... ៣

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**.......... ៣

ក- ទីតាំង.......... ៣

ខ- ដែននេសាទ.......... ៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស.......... ៣

ឃ- ធនធានជលផល.......... ៤

**៤- ការធ្វើនេសាទ**.......... ៤

ក- អ្នកនេសាទ.......... ៤

ខ- ឧបករណ៍នេសាទ.......... ៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ.......... ៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**.......... ៧

**ក- ទស្សនៈវិស័យ**.......... ៧

**ខ- គោលបំណង**.......... ៧

**គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**.......... ៧

**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**.......... ៧

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ.......... ៧

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.......... ៨

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល.......... ៨

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ.......... ៩

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល.......... ១០

គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍.......... ១១

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.......... ១២

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.......... ១២

គ៩- ផែនការគ្រប់គ្រងព្រៃកោកាង.......... ១៣

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**.......... ១៤

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.......... ១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ.......... ១៥

គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ.......... ១៦

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ.......... ១៧

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**.......... ១៨

គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ.......... ១៨

គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ.......... ១៨

**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**....................១៩
គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន....................១៩
គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍....................២០
**ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**....................២០
**ង. ផែនការយុទ្ធសាស្ត្រ**....................២១
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រយៈពេល៣ឆ្នាំ**....................២២
**តារាងពេលវេលាការងារ**....................២៩

# ផែនការគ្រប់គ្រង
# តំបន់អភិរក្សសហគមន៍នេសាទ

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទកែប ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ និងបានបោះឆ្នោតឡើងវិញនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។ ហើយត្រូវបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ ១៤០ ប្រក.កសក ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៣។

សហគមន៍នេសាទកែប មានទីតាំងស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប។ មានសមាជិកសហគមន៍នេសាទសរុបចំនួន១១១នាក់ ស្រី៤១នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន១១១គ្រួសារ សហគមន៍នេសាទនេះមានគណៈកម្មការចំនួន៩នាក់ ស្រី៣នាក់ និងមានក្រុមល្បាត ចំនួន៥នាក់។

កន្លងមកនេះ សហគមន៍នេសាទបានរៀបចំ និងអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ បានចូលរួមកំណត់ព្រំប្រទល់និងធ្វើផែនទីតំបន់នេសាទសហគមន៍ បានរៀបចំបញ្ជីឈ្មោះសមាជិក បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ និងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត ដោយមានការឯកភាពគ្នាក្នុងចំណោមគណៈកម្មការសហគមន៍នេសាទទាំងអស់។ ក្រៅពីនេះសហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗ រួមមានការចូលរួមប្រជុំ និងបិទប្រកាសផ្សព្វផ្សាយផែនទីតំបន់សហគមន៍នេសាទ ការរៀបចំតំបន់អភិរក្សជលផលរបស់សហគមន៍នេសាទ រៀបចំធនាគារក្តាមសេះ ការចាប់ផ្តើមអនុវត្តសកម្មភាពមុខរបរ និងសកម្មភាពទេសចរណ៍ជលផលរបស់សហគមន៍នេសាទ ចូលរួមប្រជុំផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលនានា ការរៀបចំក្រុមល្បាតរបស់សហគមន៍នេសាទ រួមសហការជាមួយសមត្ថកិច្ចជលផលអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធដទៃទៀតក្នុងការចុះល្បាតទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទដែលកើតមាននៅក្នុងតំបន់សហគមន៍នេសាទ។ រហូតមកដល់បច្ចុប្បន្ននេះ សហគមន៍នេសាទបានអនុវត្តសកម្មភាពតាមផែនការគ្រប់គ្រងរបស់ខ្លួន ដោយទទួលបានវឌ្ឍនភាពប្រកបដោយជោគជ័យក្នុងការកាត់បន្ថយសកម្មភាពបទល្មើសនេសាទនានា។

ទោះបីជាទទួលបានលទ្ធផលដូចខាងលើក្តី សហគមន៍នេសាទកែប នៅតែជួបប្រទះបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋនិងការគ្រប់គ្រងមានដូចខាងក្រោមៈ

- ផលនេសាទថយចុះបណ្តាលពីសកម្មភាពនេសាទលើសកម្រិត ការនេសាទដោយប្រើប្រាស់ស្បៃមុង តម្រូវការកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញ មានដូចជា ទូកអូសស្រទាប់បាតនៅទឹករាក់ ការប្រើប្រាស់ឧបករណ៍ឆក់ជាដើម ព្រមទាំងការប្រជែងគ្នាក្នុងការនេសាទរវាងសកម្មភាពនេសាទខ្នាតតូចនេសាទជាប្រពៃណី និងនេសាទខ្នាតធំ។ សហគមន៍នេសាទសង្កេតឃើញថា បញ្ហានេះបានជះឥទ្ធិពលដល់ផលចាប់ត្រីនិងវារីសត្វសមុទ្រផ្សេងៗមានការថយចុះ
- ការថយចុះប្រព័ន្ធអេកូស៊ីស្ទែមជលផលសមុទ្រ ដូចជាជម្រកជលផលសមុទ្រ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្មដែលកំពុងរងផលប៉ះពាល់ពីការនេសាទ ដែលបំផ្លិចបំផ្លាញការអភិវឌ្ឍឬការប្រើប្រាស់ដីមិនសមស្របជាដើម
- សមត្ថភាពនិងចំណេះដឹងរបស់គណៈកម្មការនិងសមាជិក នៅមានកម្រិត ដូចជាខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងខ្វះការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន ឬសហគ្រប់គ្រងនៅមានកម្រិត

- ការជ្រើសរើសមុខរបរមានកម្រិត និងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយ និងផលចាប់ពីធម្មជាតិ អស្ថេរភាពតម្លៃផលិតផលកសិកម្មដែលកំណត់ដោយឈ្មួញកណ្ដាលក្នុងតំបន់ ពិបាកក្នុងការទទួលបានតម្លៃបន្ថែមលើផលផលិតផលដោយសារគុណភាពផលិតផលនិងការកែច្នៃ ខ្វះទន់ក្នុងការចាប់ផ្ដើម និងជំនាញលើមុខរបរ ដូចជាការបង្កើតសេវាទេសចរណ៍ជលផល វារីវប្បកម្មដែលមិនប្រើចំណីជាដើម
- ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិដែលប៉ះពាល់លើការប្រកបរបរនេសាទ សេវាទេសចរណ៍ជលផលលំនៅដ្ឋាន និងគុណភាពទឹកសមុទ្រ ដូចជា កំណើនជាតិពុលក្នុងទឹក កំដៅទឹក សមុទ្រអាចនឹងប៉ះពាល់ដល់ទេសចរណ៍ជលផល និងវារីវប្បកម្ម
- ការចោលសំរាម ផ្លាស្ទីក និងកាកសំណល់នានាដែលនាំឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ បង្កឱ្យមានជាតិពុល និងសោភណ្ឌភាពនៅក្នុងសហគមន៍នេសាទ
- សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ដូចជា ការងាររដ្ឋបាល ការអនុវត្តសកម្មភាពការងារគ្រប់គ្រង ការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត
- លទ្ធភាពចូលរួមអនុវត្តច្បាប់មានកម្រិត ដោយខ្វះមធ្យោបាយ ដូចជា ឧករណ៍ទំនាក់ទំនងរាយការណ៍ ទូកល្បាតដែលធននឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ស្ដីពីជលផលមិនបានជិតដល់ជាប្រចាំ។

ដូច្នេះទាមទារការរៀបចំកែសម្រួលឡើងវិញ នូវផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទកែប ខែមករា ឆ្នាំ២០២៣ ដល់ ខែធ្នូ ឆ្នាំ២០២៥ លេខ០៦៣ ជផ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ដោយរៀបចំផែនការសកម្មភាពសំខាន់ៗបន្ថែម និងថវិកាប៉ាន់ប្រមាណ ផ្ដោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការចុះបញ្ជីនាវា នេសាទ ការប្រមូលព័ត៌មាន (ទូកនេសាទ ឧបករណ៍នេសាទ និងផលនេសាទ) និងការកាត់បន្ថយការប្រើប្រាស់ ឧបករណ៍នេសាទខុសច្បាប់។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន ៣០៤៤ នាក់ ស្រី ១១៦៩ នាក់ ក្នុងនោះមានចំនួន ៦៤០ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ៩៩% និងកាន់សាសនាឥស្លាម ១%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរ.៦.នាក់ស្រី៤នាក់ កម្រិត ថ្នាក់បឋមសិក្សាចំនួន៧០នាក់ ស្រី៤០នាក់ កម្រិតវិទ្យាល័យចំនួន៤នាក់ ស្រីចំនួន២នាក់ និងកម្រិតឧត្តមសិក្សា០០នាក់

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៣នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន០០ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១នាក់ ស្រី០០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៥នាក់ ស្រី២នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន១០នាក់ ស្រី៥នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន០០នាក់ ស្រី០០នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទ ចំនួន ១៤៥ គ្រួសារ

- ធ្វើស្រែ ចំនួន ១៧៥ គ្រួសារ ទំហំ៧៥ ហិកតា
- ធ្វើចំការ ចំនួន១០ គ្រួសារ ទំហំ០,៣-០,៨ហិកតា
- ដាំបន្លែ ចំនួន ២០ គ្រួសារ
- ចិញ្ចឹមសត្វ ចំនួន៥៨គ្រួសារ
- ធ្វើវារីវប្បកម្ម ចំនួន ៧ គ្រួសារ
- ជាងផ្ទះ ចំនួន ៣ គ្រួសារ
- លក់ដូរ ចំនួន ៧៥ គ្រួសារ
- កម្មករ ចំនួន១១៥ គ្រួសារ
- ធ្វើសិប្បកម្ម ចំនួន៤ គ្រួសារ (បង្គាក្រៀម ត្រីងៀតឬត្រីប្រលាក់ ក្តាមប្រៃ និងគី)
- លក់ដូរវត្ថុអនុស្សាវរីយ៍ចំនួន០គ្រួសារ។
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ១០ ៤០០ ០០០រៀល ។

## ៣ កន្លែងសហគមន៍នេសាទ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងសហគមន៍នេសាទកែប ជាតំបន់គ្រប់គ្រងជលផលសមុទ្រ មានកន្លែងនេសាទតាមឆ្នេរ កន្លែងការពារ កន្លែងអភិរក្សជលផល ស្មៅសមុទ្រ នាទីព្រៃកោងកាង វាលភក់ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប។ សហគមន៍នេសាទកែប មានទំហំ **២៧០** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ។

សហគមន៍នេសាទកែប មានព្រំប្រទល់ ៖

- ខាងជើងជាប់នឹងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
- ខាងត្បូងជាប់នឹងសមុទ្រ ខេត្តកែប
- ខាងកើតជាប់នឹងសមុទ្រ ខេត្តកែប
- ខាងលិចជាប់នឹងសមុទ្រ ខេត្តកែប។

### ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទកែប មានលំហសមុទ្រចំនួន១ ព្រែកចំនួន៧ វាលភក់ចំនួន១ និងនាទីព្រៃកោងកាងចំនួន១ គឺៈ

| | | |
|---|---|---|
| - លំហសមុទ្រ | ទំហំ ៣២៦,៨ ហិកតា | នេសាទពេញមួយឆ្នាំ |
| - ព្រែកហាងទឹកត្រី | ប្រវែង ៥៧ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - ព្រែកអ៊ូតាវ៉ាត | ប្រវែង ១០២ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - ព្រែកកិញតាម៉ុងចាស់ | ប្រវែង ១០០ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - ព្រែកកិញតាម៉ុងថ្មី | ប្រវែង ៧៨ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - ព្រែកកិញថ្មី | ប្រវែង ៨៥ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - ព្រែកកិញត្រង់ | ប្រវែង ៦៩ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - ព្រែកកែប | ប្រវែង ៩៨ ម៉ែត្រ x ១០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ |
| - វាលភក់ | ទំហំ ៦០ ហិកតា | នេសាទពេញមួយឆ្នាំ |
| - នាទីព្រៃកោងកាង | ទំហំ ១៨ ហិកតា | នេសាទពេញមួយឆ្នាំ ។ |

គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល

សហគមន៍នេសាទកែប បានសម្រេចបង្កើតកន្លែងអភិរក្សជលផល២កន្លែង ទំហំសរុប៤២ហិកតា ស្ថិតនៅក្នុងកន្លែងសហគមន៍នេសាទកែប។ កន្លែងអភិរក្សជលផលនេះ ត្រូវបានធ្វើរៀបចំនិងគ្រប់គ្រងដោយសហគមន៍នេសាទ។

**ឃ. ធនធានជលផល**

ប្រទេសកម្ពុជា ធនធានជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀងនិងសេដ្ឋកិច្ច ហើយធនធានជលផលនេះ ផ្តល់ជាអាហារនិងមុខរបរនៃការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍នេសាទកែប បានឱ្យដឹងថាបច្ចុប្បន្នធនធាជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ។

**ប្រភេទត្រីសមុទ្រ ៖** ត្រីក្តចិន ត្រីក្បក ត្រីក្អក ត្រីស្តុង ត្រីក្រហម ត្រីផ្ទោង ត្រីឆ្លាម ត្រីបបែល ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកាឡាង់ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រែ ត្រីទក់សមុទ្រ ត្រីប្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក។

**ប្រភេទវារីសត្វសមុទ្រ ៖** បង្គា បង្កង បង្កងកន្ទប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹកគ្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ទាយ បាលង្កាស កញ្ចា អន្ទង់ ខ្ចឹង ផ្សោតស ផ្សោតខ្មៅ ។ល។

**ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៉ឹង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចេរ ដើមឡេវអាវ ចាក ប្រង់ ដើមដូងទឹក ផ្កាថ្ម ស្មៅសមុទ្រ ។ល។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១១១នាក់ ស្រី៤១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍៣៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៨៥នាក់ ក្នុងមួយឆ្នាំ។

ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួន ឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវនេសាទ |
|---|---|---|---|---|---|
| មងត្រី | ម៉ែត្រ | ២៨ | ៩០ម៉ែត្រ/គ្រួសារ | ៣,៥ស.ម×៥០០ម | ពេញមួយឆ្នាំ |
| លបក្តាម | លប | ៧ | ៥០០គ្រឿង/គ្រួសារ | ២០០ | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៨ | ២៥០គ្រឿង/គ្រួសារ | ៣,៨ស.ម×៥០០ម | ពីខែធ្នូ ដល់ខែមករា |
| សន្ទូចរនង | ផ្លែ | ៤ | ២៧សេះ | ៥០០ | ពីខែមេសា ដល់ខែវិច្ឆិកា |
| ឈិបរុញដៃ | គ្រឿង | ៥ | ១០០-២០០ផ្លែ/គ្រួសារ | ១គ្រឿង | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ខ្សែ | ១៤ | ១គ្រឿង/គ្រួសារ | ១០០០ផ្លែ | ពីខែវិច្ឆិកាដល់ខែមេសា |
| លបត្រី | លប | ៥ | ៤រនាស់/គ្រួសារ | ១៥លប | ពីខែមិថុនា ដល់ខែមករា |
| រាវបង្គា | នាក់ | ៣៨ | ២០០នាក់ | | ពេលទឹកនាច |
| ឈ្នាង | គ្រឿង | ២ | ២០នាក់ | គ្រឿង/នាក់ | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦៨គ្រឿង | ៧០០-១០០០គីឡូក្រាម | ៦-១៣ សេះ |
| ទូកអុំនិងចែវ | ២គ្រឿង | ៧០-១០០គីឡូក្រាម | - |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ឧបករណ៍នេសាទ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងត្រី | ម៉ែត្រ | ២៨ | ៩០ម៉ែត្រ/គ្រួសារ | ៤ដៃ(១ដៃ=៦០ម) | **ពេញមួយឆ្នាំ** |
| លបក្តាម | លប | ៥ | ៣៥០ម៉ែត្រ/គ្រួសារ | ៥០០-១០០០ | **ពេញមួយឆ្នាំ** |
| មងបង្គា | ម៉ែត្រ | ១៧ | ១៨០ម៉ែត្រ/គ្រួសារ | ៤ដៃ(១ដៃ=៦០ម) | ពីខែធ្នូ ដល់ខែមករា |
| រនងខ្យង | ផ្លែ | ៥ | ១៥០ម៉ែត្រ/គ្រួសារ | ២០០០ | **ពីខែមេសាដល់ខែមករា** |
| ឈិបរុញដៃ | គ្រឿង | ៤ | ៣៥០ម៉ែត្រ/គ្រួសារ | ១គ្រឿង | ពេញមួយឆ្នាំ |
| សន្ទូចមឹក | ខ្សែ | ៥ | ២៥០លប/គ្រួសារ | ២ខ្សែ=១២ផ្លែ | **ពីខែវិច្ឆិកាដល់ខែមេសា** |
| រាវបង្គា | នាក់ | ២០ | ២០០នាក់ | | ពេលទឹកនាច |
| ឈ្នាង | គ្រឿង | ១ | ៥០០ម៉ែត្រ/គ្រួសារ | គ្រឿង/គ្រួសារ | **ពេញមួយឆ្នាំ** |

(ម = ម៉ែត្រ)

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥០ គ្រឿង | ៤០០គីឡូក្រាម | ៦-១៣ សេះ |
| ម៉ូតូ | ១០គ្រឿង | | |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួននាក់ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងក្តាម | ម៉ែត្រ | ១៥ | ២៧៥ម៉ែត្រ/គ្រួសារ | ៥០០ម៉ែត្រ/១នាក់ | វិច្ឆិកាដល់មករា |
| លបក្តាម | លប | ២ | ៣៥០ម៉ែត្រ/គ្រួសារ | ៣០០-៥០០លប/នាក់ | តុលាដល់មេសា |
| លបត្រី | ម៉ែត្រ | ៨ | ២៥០លប/គ្រួសារ | ២០-៣០លប/នាក់ | ពេញរដូវនេសាទ |
| លូកក្តាមថ្ម ក្តាមជ័រ | នាក់ | ៦ | ៥០០លប/គ្រួសារ | | វិច្ឆិកាដល់មករា |
| ឈិបរុញដៃ | គ្រឿង | ៤ | ១-២គ្រឿង/គ្រួសារ | ១គ្រឿង/នាក់ | ពេញរដូវនេសាទ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១២ គ្រឿង | ៤០០ គីឡូក្រាម | ៤,៥-៦ សេះ |
| ម៉ូតូ | ៨ គ្រឿង | | - |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | មរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ២៥០០ គីឡូក្រាម | ១៨០០ គីឡូក្រាម | ៤៣០០ គីឡូក្រាម |
| បង្គា | ១៥៥០ គីឡូក្រាម | ១២០០ គីឡូក្រាម | ២៧៥០ គីឡូក្រាម |
| ក្តាម | ៨០០ គីឡូក្រាម | ៨០០ គីឡូក្រាម | ១៦០០ គីឡូក្រាម |
| មឹក ខ្យងនិងគ្រែងឈាម | ១០០០ គីឡូក្រាម | ៨០០ គីឡូក្រាម | ១៨០០ គីឡូក្រាម |
| សរុប | ៥៨៥០ គីឡូក្រាម | ៤៦០០ គីឡូក្រាម | ៩៦៤៤ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទកែប មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលសមុទ្រ ប្រកបដោយ សមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ដែលជាកន្លែងសហគមន៍នេសាទ នាទីព្រៃកោងកាង វាលភក់ និងកន្លែងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានជលផល ។

### គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ

**ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង**

**គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចជាប់ដីគោក ទំហំ៣០ម៉ែត្រ x ៣០ម៉ែត្រ ចំណុចនិយាមកា 427553-1159993 ស្ថិតក្នុងភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាព និងអ្នកពាក់ព័ន្ធ | -មានការចូលរួម<br>-មានការគាំទ្រ | ៥០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កក្កដា ២០២៦ | ធ្នូ ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១៣ម ធ្វើពីបេតុង រួមផ្សំគ្រឿងឈើ ប្រក់ក្បឿង បន្ទប់មួយជ្រុង រៀបជញ្ជាំងឥដ្ឋ និងមានបង្គន់អនាម័យ | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងសហគមន៍នេសាទ | ៥០០០០ | | កក្កដា ២០២៦ | ធ្នូ ២០២៨ |
| រៀបចំតបណ្តាញអគ្គិសនី | មានថាមពលអគ្គិសនីធ្វើការ | ១៥០០ | | កក្កដា ២០២៦ | ធ្នូ ២០២៨ |
| រៀបចំប្រព័ន្ធទឹកស្អាត ស៊ីទែនជ័រ ២ ចំណុះ ៣៥០០លីត្រ | មានទឹកស្អាតប្រើប្រាស់ | ១២០០ | | | |
| ទិញសម្ភារសហគមន៍នេសាទ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារសម្រាប់ធ្វើការ | ១៥៥០ | | | |

(ម = ម៉ែត្រ)

គ២- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្ដាហ៍ទី១នៃខែ រៀងរាល់ខែឬត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | មករា ២០២៦ | ធ្នូ ២០២៨ |
| ចូលរួមប្រជុំជាមួយអាជ្ញាធរសង្កាត់ ក្រុង ឬស្ថាប័នពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្ដល់របាយការណ៍លទ្ធផលការងារ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍សង្កាត់ | ៥៤០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | មករា ២០២៦ | ធ្នូ ២០២៨ |
| ចូលរួមប្រជុំជាមួយបណ្ដាញស.ន ថ្នាក់ក្រុង ឬថ្នាក់ខេត្ត | -ទទួល និងផ្ដល់ព័ត៌មាន<br>-មានដំណោះស្រាយនានា | ៥៥០ | -បណ្ដាញស.ន<br>-គណៈកម្មការ | មករា ២០២៦ | ធ្នូ ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ | - បានចុះបញ្ជីទូកម៉ាស៊ីន<br>- ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសនេសាទថយចុះ | ៦០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | មករា ២០២៦ | ធ្នូ ២០២៨ |
| ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | -មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ | ៩០០ | -គណៈកម្មការ<br>-សមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| -សម្ភារការិយាល័យ<br>- LCD with Screen<br>-ទិញក្រដាស់ ប៊ិច ព្រីនឯកសារ កូពី<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ២០០០ | គណៈកម្មការ | មករា ២០២៦ | ធ្នូ ២០២៨ |

(ស.ន = សហគមន៍នេសាទ)

**គ៣- ផែនការផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល**

ផែនការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១. ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្ដីពី ៖<br>-ច្បាប់ស្ដីពីជលផល ច្បាប់ស្ដីពីសហគមន៍កសិកម្ម ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូល | ២៥៨០ | គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន | មករា-មិថុនា/ រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| -លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ<br>-ការរៀបចំនិងទុកដាក់សម្រាម<br>-បទពិសោធន៍នានាទទួលបាន | រួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | | ជំនាញជលផល, អង្គការដៃគូ | | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | មករា ២០២៦ | ធ្នូ ២០២៨ |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | | |
| ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជី ទូកម៉ាស៊ីន | សមាជិកសហគមន៍នេសាទបានចុះបញ្ជីទូកម៉ាស៊ីន តាមច្បាប់ | ៤៥០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មករា ២០២៦ | ធ្នូ ២០២៨ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជន ក្រុមស្ត្រី និងប្រជាពលរដ្ឋចូលជាសមាជិកសហគមន៍សហគមន៍នេសាទកែប | -ក្រុមយុវជន និងប្រជាពលរដ្ឋចូលជាសមាជិកសហគមន៍នេសាទ<br>-មានការចូលរួមគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ៩០០ | | | |
| ២. ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ និងរបាយការណ៍<br>-គម្រោងស្នើសុំថវិកា និងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈសហគមន៍នេសាទនិងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ១៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មករា ២០២៦ | ធ្នូ ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ(២នាក់) | ៣៦០ | គណៈកម្មការស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| វគ្គបណ្តុះបណ្តាលពីៈ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានជលផល<br>-សិទ្ធិមូលដ្ឋានលើធនធានជលផល | គណៈសហគមន៍នេសាទនិងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មករា ២០២៦ | ធ្នូ ២០២៨ |
| វគ្គបណ្តុះបណ្តាលយេនឌ័រ និងការវិភាគយេនឌ័រ | គណៈសហគមន៍នេសាទសមាជិកស.ន ប្រជាពលរដ្ឋ បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មករា ២០២៦ | ធ្នូ ២០២៨ |
| វគ្គបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ | | ៥០០ | | | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | | ៥០០ | | | |

(ស.ន = សហគមន៍នេសាទ)

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍កែប | ពេញរដូវនេសាទ | មងត្រីក្បក | ក្រឡា ៣,៥ស.មឡើង | ៥០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | មងត្រីឆ្កួង | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្អុក | ក្រឡា ៩ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីអណ្តាតឆ្កែ | ក្រឡា ៥,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីចាប | ក្រឡា ៦ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបបែល | ក្រឡា ១៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីព្រលួស | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីប្រខុប ឬត្រីកាម៉យ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាប៉ាស់ ឬត្រីដូរអង្ករ | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្បាន្ត | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីផ្ទោង | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្ទាំង | ក្រឡា ៤ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងក្តាម | ក្រឡា ៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងប៉ាកាំង ឬបង្កងកន្ធប | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាម៉ុង | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្ទុយរឹង | ក្រឡា ៤,៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីការ៉ាវ | ក្រឡា ៧ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបេកា | ក្រឡា ៨ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងត្រីសំប៉ាន | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីគូន | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា១ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា៣ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងហ៊ុម | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | លបមឹក | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបក្តាម | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបបង្គា | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបខ្យង | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបត្រី | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបត្រីតុកកែ | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបប្រឹសច្រើន/កន្ទុយកណ្តុរ | ក្រឡា ៣ ស.មឡើង | ២០លប/គ្រួសារ | |
| | | អួនត្រីស | ក្រឡា ២,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនត្រីកាឡេងតេង | ក្រឡា ១,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនហ៊ុមកៀនច្រាំង | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនខ្ចូវ ឬមងខ្ចូវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍កែប | ពេញរដូវនេសាទ | អួនកេរ៍ ឬមងកេរ៍ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ |
| | | សន្ទូចរនងត្រី | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងបបែល | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | រនងធ្លាក់មឹក | - | ៥០០គ្រ/គ្រួសារ | |
| | | សន្ទូចត្រីបេកា | - | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចដៃ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | | ឈិបរុញដោយដៃ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |
| | | រាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | រាវងាវកក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្តាមថ្ម ជីវ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ, គ្រ = គ្រាប់) (ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

**គ៥- ផែនការទប់ស្កាត់បទល្មើសជលផល**

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយៈ<br>-តាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-បិទឯកសារ ១ដង/ឆ្នាំ<br>-ចែកឯកសារ<br>-ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ១៥៦០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែ ឬឆមាស(មករានិងមិថុនា/រៀងរាល់ឆ្នាំ) | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣៦០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>អង្គភាពពាក់ព័ន្ធ | មករា ២០២៦ | ធ្នូ ២០២៨ |
| អនុវត្តន៍ផែនការៈ (រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធនិងអង្គការដៃគូ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១០៣៦៨ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ<br>អង្គការដៃគូ | មករា ២០២៦ | ធ្នូ ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| (៤ដង/ខែ = ១៤៤/ដង) | | | | | |
| មធ្យោបាយនិងសម្ភារ<br>-សាំង និងប្រេងបាត<br>-អាវ ស្បែកជើង មួក<br>អាវភ្លៀង អាវពោង ពិល<br>អាយកូម ម៉ាស៊ីនថត<br>កែវយឺត កាតទូរស័ព្ទ | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣៣៤៦ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| ទិញទូកស្ទាច់និងម៉ាស៊ីនថ្មី ចំនួន២គ្រឿង | មានមធ្យោបាយចុះល្បាត | ៤០០០ | សហគមន៍នេសាទ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| ទិញអូប័រនិងម៉ាស៊ីនកម្លាំង ៤០សេះ ចំនួន១គ្រឿង | | ៦០០០ | | | |

**គ៦- ផែនការកែលម្អកន្លែងសហគមន៍នេសាទ**

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ (ហិកតា) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទ<br>សហគមន៍កែប | ៣២៦,៨ | ៣២៦,៨<br>ហិកតា | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ និងអ្នកពាក់ព័ន្ធ | ១០០ | មករា<br>២០២៦ | ធ្នូ<br>២០២៨ |
| 425816-1158915<br>425947-1158952 | | | សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ៣ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល) | ៩០០ | | |
| 426054-1159016<br>426109-1159099 | 427460-1159624<br>427202-1159454 | | ស្លាកសញ្ញាផ្សព្វផ្សាយ ១០ផ្ទាំង១២០ស.មx ១០០ស.ម គ្រឿងដែក(ដែកមូល) | ៧០០ | | |
| 426164-1159220 | 426887-1159288 | | ចុះរកទីតាំងជាក់ស្តែងតាមនិយាមកា | ៥០០ | | |
| 426642-1159534<br>427154-1159753 | 426478-1159083<br>426862-1158958 | | បោះបង្គោលព្រំប្រទល់កន្លែងសហគមន៍នេសាទលើគោក៦បង្គោល ធ្វើពីបេតុង | ៩០០ | | |
| 427575-1160030<br>428018-1160299<br>428528-1160428<br>428528-1160217<br>428089-1160045<br>427759-1159863 | 427218-1158901<br>427540-1158929<br>427786-1158964<br>428220-1158995<br>428355-1157912<br>426014-1157912 | | បោះបង្គោលព្រំប្រទល់កន្លែងសហគមន៍នេសាទក្នុងទឹក១៧បង្គោល សរសរមូល ធ្វើពីបេតុងមុខកាត់ ៣,៥ស.ម កម្ពស់៨ម៉ែត្រ | ៨៥០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំត្រូវអភិរក្ស (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អភិរក្សជលផល ៦ ហិកតា<br>426679-1159298<br>426588-1159508<br>426832-1159624<br>426913-1159416 | ៦ | -កោងកាង<br>-ក្ដាមថ្ម<br>-អាវភក់<br>-ត្រី<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផល និងហាមឃាត់ដល់ប្រជាពលរដ្ឋ ឱ្យបានទូលំទូលាយ | ២០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | ចុះរកទីតាំងដាក់ស្ដែងតាមនិយាមកា | ៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផល ធ្វើពីស៊ីម៉ង់គ្រឿងដែក(សាជី)៤បង្គោល | ៣២០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣០០ | | |
| | | | សង់ប៉មយាមកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងឈើប្រក់ហ្វីប្រូស៊ីម៉ង់ | ៧០០ | | |
| អភិរក្សជលផល ១៣ ហិកតា<br>427459-1157913<br>427054-1157912<br>427047-1158235<br>427443-1158240 | ១៣ | -ត្រី<br>-ស្មៅសមុទ្រ<br>-គ្រែងឈាម<br>-ក្ដាមសេះ<br>-ជីវចម្រុះ | ផ្សព្វផ្សាយកន្លែងអភិរក្សជលផលនិងហាមឃាត់ឱ្យបានទូលំទូលាយ | ២០០ | | |
| | | | ចុះសិក្សាប្រមូលព័ត៌មានជលផល | ៥០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផល ធ្វើពីស៊ីម៉ង់ គ្រឿងដែកចំនួន៤បង្គោល | ៣២០០ | | |
| | | | ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុង ចំនួន៥០ ប្រអប់ | ១៥០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣០០ | | |

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្ដាមសេះ ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងសហគមន៍នេសាទកែប ២ ហិកតា<br>426292-1158600<br>426443-1158618<br>426468-1158489<br>426311-1158473 | សាកល្បង ៥០ម x ៥០ម | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយ ដើម្បីប្រមូលក្ដាមសេះពង | ៣៦០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | សាងសង់ស្ថានីយ៍១កន្លែង ៣ម៉ែត្រx៤ម៉ែត្រ និងស្ពានដើរជុំវិញស្ថានីយ៍ ធ្វើពីគ្រឿងឈើ និងសម្ភារជាង | ១២០០០ | | |
| | | បោះបង្គោលព្រំកន្លែងការពារក្ដាមសេះនិងព័ទ្ធស្បៃមុង | ៥០០ | | |
| | | ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុង ចំនួន៥០ប្រអប់ | ៥០០០ | | |
| | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |

(ម = ម៉ែត្រ)

គ៩-ផែនការគ្រប់គ្រងព្រៃកោងកាង

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ | ២២ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | បោះបង្គោលព្រំព្រៃកោងកាង ធ្វើពីបេតុង ១០ស.ម x ១០ស.ម x ១,៥ម ចំនួន២០ ដោយសរសេរអក្សរ ព្រំប្រទល់ព្រៃកោង កាងសហគមន៍នេសាទកែប | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿង ដែក ចាក់បេតុង | | ៨០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | ថែរក្សា ការពារ | | | | |
| វាលភក់ស្ថិតក្នុងកន្លែងនេសាទសហគមន៍ | ២៣ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | មករា ២០២៦ | ធ្នូ ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងដាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាស្តីពីផែនទីព្រៃកោងកាង ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿងដែក ចាក់បេតុង | | ៨០០ | | |
| | | | រៀបចំថ្នាលបណ្តុះកូនកោងកាង បង្គោលឈើ និងស្បៃ ១០ម x ២០ម | | ១០០០ | | |
| | | | បណ្តុះ ដាំ និងថែទាំដើមកោងកាង១០ហិកតា ៧០០០០ដើម (១ហិកតា×៧០០០ដើម) | | ៧០០០០ | | |
| | | | ដាំកូនកោងកាងចំនួន១៥នាក់×៨,៥ ដុល្លារ/ថ្ងៃ | | ៦០០០ | | |
| | | | ថែទាំដើមកោងកាង រយៈពេល៣ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ | | ១០០០ | | |
| | | | ពី៣ខែដល់៦ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ, ១ថ្ងៃ/អាទិត្យ | | ១០០០ | | |
| | | | ពី៦ខែឡើងទៅ៤នាក់×១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ | | ១២០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

**គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ**

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹមកង្កែប និងអន្ទង់ | -មានចំណេះដឹងចិញ្ចឹមកង្កែប អន្ទង់ ត្រីឆ្តង់ ត្រីតុកកែ ក្តាមថ្ម ក្តាមសេះ និងខ្យងចំពុះទា -យកទៅអនុវត្តជាក់ស្តែងបាន | ១០០០ | គណៈកម្មការនិងសមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ចិញ្ចឹមត្រីឆ្តង់ និងត្រីតុកកែ | | ១០០០ | | | |
| ចិញ្ចឹមក្តាមថ្ម ក្តាមសេះ | | ១០០០ | | | |
| ចិញ្ចឹមគ្រែងឈាម | | ៥០០ | | | |
| ចិញ្ចឹមខ្យងចំពុះទា | | ៥០០ | | | |
| កែច្នៃផលនេសាទ | -មានចំណេះដឹង -មានសុវត្ថិភាពចំណីអាហារ -មានជម្រើសមុខរបរ -បង្កើនប្រាក់ចំណូល | ១០០០ | | មករា ២០២៦ | ធ្នូ ២០២៨ |
| ចិញ្ចឹមសត្វមាន់ ទា ជ្រូក | | ៩០០ | | | |
| បច្ចេកទេសដាំបន្លែ | | ៩០០ | | | |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | | ១០០០ | | | |
| បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ | -មានចំណេះដឹង -មានមុខរបរខ្នាតតូច ឬសិប្បកម្ម -បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទេសចរណ៍ជលផល | -ក្រុមចុងភៅ -ក្រុមផ្ទះស្នាក់នៅ -ក្រុមដឹកជញ្ជូន -ក្រុមផ្ញើរយានយន្ត -ក្រុមផ្គត់ផ្គង់ផលកសិកម្ម -ក្រុមរោងលម្ហែ (កញ្ចះ) | ១០០០ | គណៈកម្មការនិងសមាជិស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ២.ទស្សនៈកិច្ចសិក្សា | | ២៥០០ | គណៈកម្មការនិងសមាជិស.ន | | |
| ៣.ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមកង្កែប និងអន្ទង់ | -មានក្រុមចិ.កង្កែប អន្ទង់ ឆ្តង់ តុកកែ -មានបន្លែផ្គត់ផ្គង់ដល់កន្លែងកំសាន្ត និងទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ក្រុមចិញ្ចឹមត្រីឆ្តង់និងតុកកែ | | | | | |
| ក្រុមចិញ្ចឹមគ្រែងឈាម | -មានក្រុមចិញ្ចឹមក្តាមថ្មនិងក្តាមសេះ -មានគ្រែងឈាម និងខ្យងចំពុះទា ផ្គត់ផ្គង់ទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | មករា ២០២៦ | ធ្នូ ២០២៨ |
| ក្រុមចិញ្ចឹមខ្យងចំពុះទា | | | | | |
| ក្រុមចិញ្ចឹមក្តាមថ្ម និងក្តាមសេះ | | | | | |
| ក្រុមកែច្នៃផលនេសាទ ដោយផ្តោតលើ ៖ -ក្រុមស្ត្រី -ជនងាយរងគ្រោះក្នុងស.ន | -មានក្រុមកែច្នៃផលនេសាទ -មានផលិតផលជលផលផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ -មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិស.ន | មករា ២០២៦ | ធ្នូ ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| ក្រុមចិញ្ចឹមសត្វមាន់ ទា ជ្រូក | -មានក្រុមដាំបន្លែ ចិញ្ចឹមសត្វ | ៥០០ | គណៈកម្មការនិង | មករា | ធ្នូ |
| ក្រុមដាំបន្លែ | -មានបន្លែ សត្វផ្គត់ផ្គង់តម្រូវការ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | សមាជិកស.ន | ២០២៦ | ២០២៨ |
| ក្រុមកសិកម្មចម្រុះ និងកសិកម្មបន្ត | -មានក្រុមកសិកម្មចម្រុះនិងបន្ត<br>-មានដំណាំចម្រុះផ្គត់ផ្គង់តម្រូវការ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | មករា ២០២៦ | ធ្នូ ២០២៨ |

(ស.ន = សហគមន៍នេសាទ)

### គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

